# របាយការណ៍អ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម

**កម្មវិធីរបស់ The Asian International Justice Initiative**

**ឆ្នាំទី១ លេខ ១៤** **សប្តាហ៍ទី១៤ (២៧-២៨ កក្កដា ឆ្នាំ២០០៩)**

## "សវនាការអង្គសេចក្តីលើករណីអតីតប្រធានមន្ទីរ ស-២១ កាំង ហ្គិចអាវ ហៅ ឌុច"



*រូបភាព : សាក្សី សួស ធី (អតីតបុគ្គលិកមន្ទីរ ស-២១ ទទួលបន្ទុកចុះបញ្ជីឈ្មោះអ្នកទោស)*

## ១. សេចក្តីសង្ខេប

*"គ្មានបុគ្គលិកមន្ទីរ ស-២១ ណាចូលចិត្តរបបនោះទេ ។ ជាការពិត... ភាពភ័យខ្លាចស្ថិតនៅជាប់ជាមួយខ្ញុំជានិច្ច"*

ដូចបានគ្រោងទុក ដំណើរការនីតិវិធីសប្តាហ៍នេះ មានរយៈពេលតែពីរថ្ងៃប៉ុណ្ណោះ ។ អង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មអតីតបុគ្គលិកមន្ទីរ ស-២១ រួមមាន លោក **គក ស្រស់** លោក **សួស ធី** និងលោក **មាស ប៉េងគ្រី** ។ កំណត់ហេតុលោក **មាស ប៉េងគ្រី** ធ្វើនៅដំណាក់កាលចៅក្រមស៊ើបអង្កេតត្រូវចាត់ជាភស្តុតាង និងអាននៅសវនាការ ដោយសារអង្គជំនុំជម្រះបានសម្រេចដកចេញនូវឈ្មោះសាក្សីមួយចំនួនពីបញ្ជីកោះហៅឱ្យផ្តល់សក្ខីកម្ម ។ សក្ខីកម្មទាំងនេះផ្តល់នូវព័ត៌មានដ៏សំខាន់ អំពីការចូលរួមរបស់ **ឌុច** ក្នុងប្រតិបត្តិការមន្ទីរ ស-២១ ព្រមទាំងដំណើរការធ្វើឯកសារអ្នកទោសចូល និងចេញ ។ ចម្លើយសាក្សីបានបង្ហាញនូវវិន័យដ៏តឹងរឹងអនុវត្តនៅមន្ទីរនេះ ។ បើទោះបីជា **ឌុច** ទទួលស្គាល់លោក **សួស ធី** ជាអតីតបុគ្គលិកនៅមន្ទីរ ស-២១ ក៏ដោយ ប៉ុន្តែគាត់បានសម្តែងភាពមន្ទិលសង្ស័យថា លោក **គក ស្រស់** មិនមែនជាអតីតអ្នកយាមនៅមន្ទីរ ស-២១ ទេ។

## ២. បញ្ហាច្បាប់ និងនីតិវិធី

### ក. សេចក្តីសង្ខេបសក្ខីកម្ម

ដំណើរការនីតិវិធីសប្តាហ៍នេះ បានបន្តដោយផ្តោតលើសក្ខីកម្មអតីតបុគ្គលិកមន្ទីរ ស-២១ មានដូចជា លោក **គក ស្រស់** លោក **សួស ធី** និងលោក **មាស ប៉េងគ្រី** ។ បើទោះបីជា **ឌុច** ទទួលស្គាល់លោក **សួស ធី** ជាអតីតបុគ្គលិកមន្ទីរ ស-២១ ក៏ដោយ

ប៉ុន្តែគាត់បានសម្តែងភាពមន្ទិលដែលថា លោក **គក ស្រស់** មិនមែនជាអតីតអ្នកយាមនៅមន្ទីរ ស-២១ ទេ ។ កំណត់ហេតុស្តាប់សក្ខីកម្មលោក **មាស ប៉េងគ្រី** នៅដំណាក់កាលចៅក្រមស៊ើបអង្កេតត្រូវបានចាត់ជាភស្តុតាង និងអាននៅសវនាការ ដោយហេតុថាអង្គជំនុំជម្រះបានសម្រេចដកចេញនូវឈ្មោះសាក្សីមួយចំនួនពីបញ្ជីកោះឱ្យផ្តល់សក្ខីកម្ម ។ នេះជាកិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះ ដើម្បីឱ្យដំណើរការសវនាការប្រព្រឹត្តទៅឆាប់រហ័ស ។ សក្ខីកម្មសង្ខេបរបស់សាក្សីមានដូចខាងក្រោម ៖

## ***សាក្សីលោក គក ស្រស់***

នៅព្រឹកថ្ងៃចន្ទ ដំណើការនីតិវិធីជជែកដេញដោលលើសក្ខីកម្មសាក្សី **គក ស្រស់** អាយុ៥៩ឆ្នាំ ជាអតីតអ្នកយាមនៅមន្ទីរ ស-២១ ។ សក្ខីកម្មនេះហាក់បង្ហាញនូវភាពមិនច្បាស់លាស់ជាច្រើន អំពីអង្គហេតុដែលបានជួបប្រទះនៅមន្ទីរ ស-២១ ។ កំឡុងពេលសួរដេញដោល លោកចៅក្រម **Lavergne** បានបង្ហាញយ៉ាងច្បាស់នូវភាពមន្ទិលសង្ស័យថា សាក្សីរូបនេះមានការចងចាំមិនសូវល្អ ។

***តួនាទីនៅមន្ទីរ ស-២១ ៖*** បន្ទាប់ពីការរៀបរាប់ដោយសង្ខេបអំពីសកម្មភាពការងារមុនចូលបក្សកុំម្មុយនីស្តកម្ពុជា សាក្សី **គក ស្រស់** លើកឡើងថា គាត់ចូលមកមន្ទីរ ស-២១ នៅចុងឆ្នាំ១៩៧៥ ។ គាត់បានថ្លែងថា ដំបូងគេឱ្យគាត់យាមគុកនៅតាខ្មៅ ។ ក្រោយមកប្តូរមកទីតាំងចុងក្រោយរបស់មន្ទីរ ស-២១ គាត់ត្រូវបានចាត់ឱ្យយាមនៅខាងក្នុង និងក្រៅបរិវេណមន្ទីរ ស-២១ ដោយឆ្លាស់វេនគ្នាមួយខែម្តង ក៏ប៉ុន្តែសាក្សីរូបនេះមិនចាំពីអាយុជាមធ្យមរបស់អ្នកយាមទីនោះ ដោយលោក **គក ស្រស់** បានប្រាប់ថា សមាជិក ៣នាក់ ក្នុងក្រុមរបស់គាត់សុទ្ធតែជាមនុស្សពេញវ័យ ។

***ស្ថានភាពឃុំឃាំងអ្នកទោស ៖*** ការរៀបរាប់របស់សាក្សី **គក ស្រស់** បានបង្ហាញពីស្ថានភាពឃុំឃាំងអ្នកទោសនៅក្នុងបន្ទប់ដោយឡែក មានលក្ខណៈស្របគ្នានឹងសក្ខីកម្មមុនៗ (អតីតអ្នករស់រានមានជីវិតពីមន្ទីរ ស-២១) ។

***ការសួរចម្លើយ និងការធ្វើទារុណកម្ម ៖*** ស្របនឹងសក្ខីកម្មរបស់សាក្សី **ម៉ម ណៃ** លោក **គក ស្រស់** បានរៀបរាប់ថា អ្នកទោសត្រូវបានសួរចម្លើយនៅខាងកើតបរិវេណមន្ទីរ ស-២១ ប៉ុន្តែបញ្ជាក់ថា គាត់មិនមែនជាអ្នកសួរចម្លើយ ហើយក៏មិនបានឃើញការសួរចម្លើយអ្នកទោសដែរ ។ សាក្សីបានលើកឡើងថា គាត់បានឃើញពីសកម្មភាពឃោរឃៅនៅមន្ទីរ ស-២១ នៅពេលឃើញអ្នកទោសមានរបួសពេញខ្នង និងឮសម្រែកអ្នកទោសដែលគេធ្វើទារុណកម្ម ។

***ការកំទេចអ្នកទោស ៖*** លោក **គក ស្រស់** បានរៀបរាប់ថា គាត់មិនចាំច្បាស់អំពីសេចក្តីលម្អិតនៃដំណើរការសម្លាប់អ្នកទោសទេ ប៉ុន្តែលោកបញ្ជាក់យ៉ាងច្បាស់ថា **ឌុច** ជាអ្នកបញ្ជាឱ្យកម្ទេចអ្នកទោស ។ សក្ខីកម្មលោក **គក ស្រស់** អះអាងពីសក្ខីកម្មរបស់សាក្សី **ហ៊ីម ហ៊ុយ** ថាអ្នកទោសសំខាន់ៗត្រូវបានសម្លាប់នៅបរិវេណមន្ទីរ ស-២១ ។

***វិន័យនៅមន្ទីរ ស-២១ ៖*** សាក្សីលោក **គក ស្រស់** បានផ្តល់សក្ខីកម្មថា អ្នកយាមត្រូវណែនាំឱ្យការពារកុំឱ្យអ្នកទោសរត់រួច ឬធ្វើអត្តឃាតខ្លួនឯង ។ ចម្លើយសាក្សីរូបនេះបានបង្ហាញពីវិន័យដ៏តឹងរឹងដែលអនុវត្តន៍នៅមន្ទីរ ស-២១ ។ បើទោះបីជាគាត់បានរៀប

រាប់ថា **ឌុច** គឺជាមនុស្សមាឌតូច រូសរាយ ហ្មត់ចត់ និងមិនបង្ខំឱ្យបុគ្គលិកធ្វើការ ក៏សាក្សីរូបនេះបានអះអាងថា **ឌុច** ធ្លាប់ចេញបញ្ជាឱ្យចាប់មនុស្សនៅមន្ទីរ ស-២១ ដែរ ចំពោះបុគ្គលិកណាដែលមានជាប់ពាក់ពន្ធ័នឹងទិន្នាការណាមួយ ។

***តួនាទីរបស់ ឌុច ក្នុងប្រតិបតិការប្រចាំថ្ងៃនៅមន្ទីរ ស-២១ :*** ក្នុងសក្ខីកម្មលោក **គក ស្រស់** បង្ហាញពីការចូលរួមរបស់ **ឌុច** ក្នុងប្រតិបត្តិការប្រចាំថ្ងៃនៅមន្ទីរ ស-២១ ។ សាក្សីបានផ្តល់សក្ខីកម្មថា **ឌុច** មិនធ្លាប់បានសួរចម្លើយ ធ្វើទារុណកម្ម ឬសម្លាប់អ្នកទោសដោយផ្ទាល់ដៃទេ ។ គួរកត់សម្គាល់ថា **ឌុច** យូៗម្តងដើរកាត់បន្ទប់ឃុំឃាំង... ហើយអើតមើល និងត្រួតពិនិត្យពីក្រៅបន្ទប់នោះ ដែលសក្ខីកម្មនេះមិនស្របនឹងសក្ខីកម្មមុនៗរបស់ **ឌុច** ប៉ុន្តែសក្ខីកម្មរបស់លោក **គក ស្រស់** មានការពិតជាមូលដ្ឋាន ហើយប្រកាន់ជំហរថា មិនដែលដើរមើលបន្ទប់ឃុំឃាំងអ្នកទោសទេ ។

***អារម្មណ៍សាក្សីអំពីតួនាទីនៅមន្ទីរ ស-២១ :*** នៅពេលសួរដេញដោលដោយលោកចៅក្រម **Lavergne** លោក **គក ស្រស់** បានអះអាងថា ការងារគាត់នៅមន្ទីរ ស-២១ គឺ *"សាមញ្ញ"* បំផុត ។ បើទោះបីជាគាត់ពុំមានតួនាទីធំដុំ ប៉ុន្តែលោក **គក ស្រស់** បានរំលឹកពី ការឈឺចាប់ *"ដ៏ធំធេង"* ។ គាត់បានបញ្ជាក់ថា គាត់មានអារម្មណ៍បង្ខិតបង្ខំគ្រប់ពេលក្នុងការបំពេញភារកិច្ច និងពុំមានលទ្ធភាពក្នុងការរត់គេចបានទេ ។

## ***សាក្សីលោក សួស ធី***

នៅរសៀលថ្ងៃច័ន្ទ អង្គជំនុំជម្រះ បានកោះហៅសាក្សីឈ្មោះ **សួស ធី** អាយុ ៥៨ឆ្នាំ ជាអតីតមន្ត្រីផ្នែករដ្ឋបាលនៅមន្ទីរ ស-២១ ។ ការបានបំរើការងារនៅមន្ទីរ ស-២១ អំឡុងពេលមន្ទីរនេះមានដំណើរការយ៉ាងសកម្ម លោក **សួស ធី** បានផ្តល់សក្ខីកម្មយ៉ាងលម្អិតពាក់ព័ន្ធនឹងដំណើរការចុះឈ្មោះអ្នកទោស និងរចនាសម្ព័ន្ធរបស់អង្គភាពនោះ ។ គួរឱ្យកត់សម្គាល់ **ឌុច** បានកោតសរសើរលើស្មារតីរបស់លោក **សួស ធី** ដែលបានរាយការណ៍ដោយស្មោះត្រង់នៅចំពោះមុខអង្គជំនុំជម្រះ ព្រមទាំងបានបញ្ជាក់ថា សក្ខីកម្មរបស់គាត់ឆ្លុះបញ្ចាំងពី *"លក្ខណៈពិតជាមូលដ្ឋាន"* ។

***ទំហំតួនាទីការងារ*** : បន្ទាប់ពីបំពេញការងារជាកងទ័ពអស់រយៈពេលប្រហែល ៤ឆ្នាំ លោក **សួស ធី** បានចាប់ផ្តើមបំរើការងារនៅមន្ទីរ ស-២១ ចាប់តាំងពីឆ្នាំ១៩៧៥ ។ ស្របតាមបញ្ជាមិត្ត **ហ៊រ** ជាមេបញ្ជាការកងវរៈសេនាតូច គាត់ត្រូវបានចាត់តាំងឱ្យផ្តួចផ្តើមចងក្រងបញ្ជីឈ្មោះអ្នកទោសនៅគុក **ប៉េ ហ្សឺ** *(គុកនគរបាលជាតិ)* ។ បន្ទាប់ពីគុកនេះបានរើទីតាំងមកតាំងនៅមន្ទីរ ស-២១ នៅចុងឆ្នាំ ១៩៧៥ ការងារគាត់ស្ថិតក្រោមការទទួលខុសត្រូវរបស់អង្គភាពការពារ ។

***ដំណើរការចុះឈ្មោះអ្នកទោស*** : ការរៀបរាប់របស់លោក **សួស ធី** អំពីដំណើរការចុះឈ្មោះ និងធ្វើបញ្ជីអ្នកទោសនៅមន្ទីរ ស-២១ គឺមានភាពស៊ីសង្វាក់នឹងសក្ខីកម្មមុនៗទាក់ទងនឹងបញ្ហានេះ ។ លោកបានឱ្យដឹងថា ជីវប្រវត្តិអ្នកទោសត្រូវបានកត់ត្រាជាពិសេសដោយផ្អែកលើថ្ងៃមកដល់ ។ បន្ទាប់មកអ្នកទោសត្រូវបានថតរូប មុននឹងនាំចូលទៅបន្ទប់ឃុំឃាំងនីមួយៗ ។ ចំណែកទីកន្លែងជាក់លាក់ឃុំខ្លួនអ្នកទោសត្រូវកត់ចំណាំ ដើម្បីសម្រួលការងារអង្គភាពសួរចម្លើយ ។ គាត់បញ្ជាក់ដ៏សមហេតុផលថា កិច្ចដំណើរការដែលបានលើកឡើងមុនៗ មិនយកមកអនុវត្តចំពោះក្រុមអ្នកទោសមួយចំនួន យោងតាម ឋានៈកម្មាភិបាលធំៗ ក្រុម

កុមារ និង *"ពួកបស្ចឹមប្រទេស"* ។ ចំពោះអតីតបុគ្គលិកមន្ទីរ ស-២១ ដែលត្រូវបានចាប់ខ្លួនត្រូវប្រព្រឹត្តក្រោមរូបភាពលាក់កំបាំង និងសម្ងាត់ ហើយមិនស្ថិតក្នុងដំណើរការចុះបញ្ជីទេ ។

***រចនាសម្ព័ន្ធអង្គការលេខ*** : លោក **សួស ធី** បានផ្ដល់ឱ្យដឹងអំពីរចនាសម្ព័ន្ធមន្ទីរសន្តិសុខ ។ គាត់បានឱ្យដឹងថា មន្ទីរ ស-២១ ត្រូវបានបែងចែកជា ៣ អង្គភាពធំៗ គឺមន្ទីរ ស-២១ (ក) ជាអង្គភាពកងសួរចម្លើយ មន្ទីរ ស-២១ (ខ) ជាអង្គភាពកងការពារ និង ស-២១ (ឃ) ជាមន្ទីរអប់រំកែប្រែនៅព្រៃ ស ។ អង្គភាពទាំងនោះស្ថិតក្រោមការមើលការខុសត្រូវទូទៅរបស់មិត្ត **ប៉េង** មិត្ត **ហ៊ រ** និង មិត្ត **ហ៊ុយ ស្រែ** ប៉ុន្តែ **ឌុច** ជាអ្នកគ្រប់គ្រង និងត្រួតពិនិត្យខ្ពស់បំផុតលើកិច្ចការរដ្ឋបាលអង្គភាពទាំងអស់នៅមន្ទីរ ស-២១ (ក) ។ **ឌុច** ទទួលស្គាល់ថា មន្ទីរសន្តិសុខអាចត្រូវបែងចែកជា ៤ អង្គភាពផ្សេងៗគ្នា ប៉ុន្តែថ្នាក់លើទទួលស្គាល់ជាផ្លូវការតែ *"មន្ទីរ ស-២១"* ប៉ុណ្ណោះ ។

***រចនាសម្ព័ន្ធទំនាក់ទំនងនៅមន្ទីរ ស-២១*** : សក្ខីកម្មលោក **សួស ធី** បានគូសបញ្ជាក់លើអង្គហេតុថា មន្ទីរ ស-២១ ត្រូវគ្រប់គ្រងតាមឋានានុក្រមដ៏តឹងតែង ។ គាត់បានបញ្ជាក់យ៉ាងដាច់ខាតថា *"ការងារទាំងអស់នៅមន្ទីរ ស-២១ ត្រូវតែមានការអនុញ្ញាតិសម្រេចពី **ឌុច**"* ។ បើទោះបីជា រាល់ទំនាក់ទំនងទាំងអស់ត្រូវធ្វើតាម *"ខ្សែចាត់តាំង"* ក៏លោក **សួស ធី** បដិសេធពីទំនាក់ទំនងដោយផ្ទាល់ជាមួយ **ឌុច** ។

***ជោគវាសនាអ្នកទោសនៅមន្ទីរ ស-២១*** : ឆ្លើយតបសំណួរលោកប្រធាន **និល ណុន** លោក **សួស ធី** ថ្លែងយ៉ាងខ្លីថា អ្នកជាប់ឃុំនៅមន្ទីរ ស-២១ រួមទាំងកុមារ ត្រូវចាត់ទុកថាស្លាប់រួចទៅហើយ ចាប់ពីថ្ងៃចូលដំបូង ។ គាត់ហាក់មិនចងចាំអំពីព្រឹត្តការណ៍កើតឡើង នៅពេលអ្នកទោសត្រូវបញ្ជូនចេញពីមន្ទីរ ស-២១ ទៅកាន់ព្រៃស ។

***ដំណើរការកំទេចអ្នកទោស*** : លោក **សួស ធី** បានលើកឡើងថា ទម្លាប់សម្លាប់អ្នកទោសត្រូវធ្វើតាមការចាត់តាំងរបស់ **ឌុច** ក្នុងនាមជាប្រធាន ។ ភស្តុតាងផ្ដល់ដោយលោក **សួស ធី** បានបំពេញបន្ថែមលើសក្ខីកម្មរបស់លោក **ហ៊ឹម ហ៊ុយ** អំពីបញ្ហានេះ ។ លោក **សួស ធី** រំលឹកពីការទទួលចំណារពីមិត្ត **ហ៊ រ** ដែលមានបញ្ជាក់ឈ្មោះអ្នកទោសយកទៅកំទេច ។ គាត់បានបញ្ជាក់យ៉ាងជាក់លាក់ថា ចំណារទាំងនោះធ្វើឡើងដោយ **ឌុច** ។ ការបែងចែកបញ្ជីឈ្មោះអ្នកទោសផ្សេងៗ ដើម្បីរៀបចំពេលវេលាយកទៅសម្លាប់ត្រូវបានធ្វើជាបន្តបន្ទាប់ ។ ទីកន្លែងឃុំខ្លួនអ្នកទោសពិតប្រាកដត្រូវកត់ត្រាទុក ដើម្បីជួយសម្រួលការងារអ្នកយាម នាំយកអ្នកទោសទៅកាន់ច្រកចេញ-ចូលបរិវេណមន្ទីរសន្តិសុខ ។ គាត់បន្ថែមថា ការចេញដំណើររបស់អ្នកទោស ត្រូវធ្វើយ៉ាងឆាប់រហ័សជាមួយនឹងការផ្ទៀងផ្ទាត់ឈ្មោះចុងក្រោយ ។ លោក **សួស ធី** បានបញ្ជាក់បន្ថែមថា កិច្ចដំណើរការនេះត្រូវប្រកាន់ខ្ជាប់ជានិច្ច លើកលែងតែអ្នកទោសមួយចំនួនទុកសម្រាប់សម្លាប់ ។

***ភាពភ័យខ្លាច និងការសម្ងាត់នៅមន្ទីរ ស-២១*** : ភាពភ័យខ្លាច និងការសម្ងាត់នៅមន្ទីរ ស-២១ បានលេចចេញយ៉ាងច្បាស់ដោយសក្ខីកម្មរបស់លោក **សួស ធី** ។ គាត់បានថ្លែងថា គាត់ស្ថិតនៅក្នុងឋានៈមួយតែងមានភាពភ័យខ្លាចចំពោះថ្នាក់លើ *"អ្នកថ្នាក់ក្រោមត្រូវភ័យខ្លាចចំពោះថ្នាក់លើ"* ។ គាត់បានឱ្យដឹងថា ការទំនាក់ទំនងរវាងអង្គភាពនិងអង្គភាព ស្ទើរតែមិនមានទេ ។ បុគ្គលិក

មន្ទីរ ស-២១ ត្រូវស្ថិតក្រោមការត្រួតពិនិត្យយ៉ាងជិតដល់ ដែលបណ្តាលឱ្យបរិយាកាសមាន *"ភាពភ័យខ្លាច"* ។ មេធាវីក្តីការពារជាតិលោក **ការ សាវុត្ថ** បានសិរតសំរាំងស្វែងរកភស្តុតាង ដើម្បីបង្ហាញពីកិច្ចការសម្ងាត់នៅអង្គភាពនេះ ។

***ការសោកស្តាយក្នុងការចូលរួមសម្លាប់អ្នកទោស :*** លោក **សួស ធី** បានឱ្យដឹងថា គាត់ *"ស្អប់ការងារនៅមន្ទីរ ស-២១"* ប៉ុន្តែដោយបញ្ជាថ្នាក់លើ. . . ដូច្នេះគាត់មិនអាចប្រកែកបានទេ ។ លោក **សួស ធី** បានថ្លែងទៅកាន់ **ឌុច** ក្នុងនាមជាប្រធានមន្ទីរ ស-២១ថា គាត់ខិតខំបំរើការងារធ្វើយ៉ាងណាឱ្យបានល្អ បើទោះបីជាគាត់មិនពេញចិត្តនឹងការងារនោះ មួយវិនាទីណាឡើយក៏ដោយ ។ បន្ទាប់មកគាត់បានបង្ហាញពីការ *"អាណិតអាសូរ"* លើមនុស្សទាំងនោះ ដែលបានចាប់ខ្លួន និងសម្លាប់ដោយគ្មានកំហុស ហើយគាត់ថែមទាំងបានសំដែងនូវការសោកស្តាយក្នុងការចូលរួមប្រព្រឹត្តបទល្មើសនៅមន្ទីរ ស-២១ ។

## សាក្សីលោក មាស ប៉េងគ្រី

នាល្ងាចថ្ងៃអង្គារ កំណត់ហេតុសួរយកចម្លើយលោក **មាស ប៉េងគ្រី** នៅដំណាក់កាលសហចៅក្រមស៊ើបអង្កេតត្រូវប្រកាសថា ជាឯកសារភស្តុតាង ។

***ការងារនៅមន្ទីរ ស-២១ :*** លោក **មាស ប៉េងគ្រី** ជាអតីតអ្នកបើកបររថយន្តនៅមន្ទីរ ស-២១ តាំងពីឆ្នាំ ១៩៧៦ ។ ការឡើងថា ការងាររបស់គាត់ស្ថិតក្រោមការគ្រប់គ្រងរបស់លោក **ហ៊ឹម ហ៊ុយ** *(ដែលជាប្រធានផ្នែក)* ។ ទោះបីជាគាត់ត្រូវបានបញ្ជាឱ្យដឹកជញ្ជូន *"បន្លែគ្រប់ប្រភេទ"* គាត់ក៏ធ្លាប់បានដឹកជញ្ជូនអ្នកទោសចូលបរិវេណមន្ទីរ ស-២១ ចំនួន២លើក និងដឹកជញ្ជូនទៅជើងឯក *"ប្រហែលម្តង ឬពីរដង"* ដែរ ។ គាត់បន្ថែមថា កាតព្វកិច្ចចម្បងរបស់គាត់ គឺដឹកជញ្ជូនបន្លែ ជ្រូក និងដឹកជញ្ជូនឈើធ្វើផ្ទះទៅជើងឯក ។

***ការដឹកជញ្ជូនអ្នកទោសចូលមន្ទីរ ស-២១ ឬជើងឯក :*** កំណត់ហេតុលោក **មាស ប៉េងគ្រី** បានឱ្យដឹងថា ការងារដំបូងរបស់លោក **ហ៊ឹម ហ៊ុយ** គឺមើលការខុសត្រូវអ្នកទោស ដោយចងដៃ និងរុំមុខ នៅពេលពួកគេដឹកចូលមន្ទីរ ស-២១ ។ កំណត់ហេតុនេះក៏បានបង្ហាញថា អ្នកទោសត្រូវចងដៃ និងរុំមុខ នៅពេលដឹកទៅជើងឯកផងដែរ ។

***ការដឹកញ្ជូនអ្នកទោសទៅមន្ទីរអប់រំកែប្រែព្រៃស :*** កំណត់ហេតុលោក **មាស ប៉េងគ្រី** បានលើកឡើងពីអង្គហេតុដែលថា បុគ្គលិកមន្ទីរ ស-២១ ត្រូវទទួលវិន័យ និងទារុណកម្ម នៅពេលប្រព្រឹត្តកំហុស ។ គាត់រំលឹកថា គាត់ត្រូវឃុំឃាំងនៅមន្ទីរ ស-២១ តាំងពីឆ្នាំ១៩៧៧ រហូតដល់ ខែមករា ឆ្នាំ១៩៧៩ ដោយសារគាត់បានធ្វើឱ្យមានគ្រោះថ្នាក់ក្រឡាប់ឡាន ។ កំណត់ហេតុនេះក៏បានរៀបរាប់យ៉ាងលម្អិតទៀតថា លក្ខខណ្ឌការងារ គឺលំបាកនៅមន្ទីរអប់រំកែប្រែព្រៃស ដែលស្រដៀងគ្នានឹងការផ្តល់សក្ខីកម្មរបស់សាក្សីមុនៗដែរ ។ អ្នកទោសជាប់ឃុំនៅមន្ទីរព្រៃសជាច្រើនត្រូវធ្លាក់ខ្លួនឈឺជាទម្ងន់ ទោះបីជាមានពេទ្យព្យាបាលពួកគេក៏ដោយ ។

***ការធ្វើទំនាក់ទំនងជាមួយ ឌុច :*** លោក **មាស ប៉េងគ្រី** បានបង្ហាញថា គាត់ជាមនុស្សតែម្នាក់ដែលបានជួប **ឌុច** នៅវត្តរៀនសូត្រក្បែរផ្ទះរបស់ **ឌុច** ។ គាត់បន្ថែមថា គាត់មិនដែលឃើញ **ឌុច** នៅមន្ទីរព្រៃសទេ ។

បន្ទាប់ពីបានស្ដាប់កំណត់ហេតុសាក្សីរូបនេះ ប្រធានអង្គជំនុំជម្រះបានផ្តល់ឱកាសឱ្យ **ឌុច** ធ្វើការសង្កេតលើរបាយការណ៍សក្ខីកម្មរបស់លោក **មាស ប៉េងគ្រី** ។ មេធាវីការពារក្តីជាតិលោក **ការ សាវុត្ថ** បានស្នើសុំអង្គជំនុំជម្រះអានសេចក្តីថ្លែងរបស់សាក្សីនៅពេល *"សម្លេងឡើងវិញទៅជើងឯក"* ។ ទោះបីជា សំណើរបស់លោក **ការ សាវុត្ថ** ត្រូវបានអនុញ្ញាត ក៏អង្គជំនុំជម្រះបានប្រកាសផ្អាកនីតិវិធីភ្លាមៗ ដោយសារអត្តសញ្ញាណរបស់សាក្សីមិនទាន់ផ្តល់សក្ខីកម្មត្រូវការពារ ។

## ២. បញ្ហាផ្នែកច្បាប់កើតមានកំឡុងពេលសវនាការ

***សាក្សីបន្តបង្ហាញសក្ខីកម្មសាក្សីមុនៗ :*** កំឡុងនីតិវិធីកាលពីសប្តាហ៍មុន បញ្ហាពាក់ព័ន្ធនឹងការបង្ហាញសក្ខីកម្មសាក្សីមុនៗត្រូវកើតឡើងម្តងទៀតនៅថ្ងៃអង្គារ នៅពេលដែលលោក **សួស ធី** បង្ហាញពីការយល់ដឹងលើសក្ខីកម្មរបស់លោក **គក ស្រស់** ។ គួរកត់សម្គាល់ លោក **សួស ធី** បានបង្ហាញពីសក្ខីកម្មរបស់លោក **គក ស្រស់** ដែលទើបនឹងផ្តល់សក្ខីកម្មមុននេះបន្តិច ។ ជាងនេះទៀតនៅព្រឹកថ្ងៃច័ន្ទ មុនពេលផ្តល់សក្ខីកម្មលោក **គក ស្រស់** ក្រឡាបញ្ជីបានប្រកាសពីអត្តសញ្ញាណសាក្សី **សួស ធី** ថាត្រៀមខ្លួនជាស្រេច *"ក្នុងការផ្តល់សក្ខីកម្មរបស់ខ្លួន"* ។ យោងតាមក្រុមអ្នកឃ្លាំមើលតុលាការបានឱ្យដឹងថា បញ្ហានេះផ្ទុយនឹងវិធាន ៨៨(២) នៃវិធានផ្ទៃក្នុង ។ ការរំលោភវិធាននេះ គឺជាបញ្ហាចោទទាក់ទងនឹងវិធានការសមស្រប ដែលត្រូវបង្កើតឡើងដើម្បីធានាឱ្យមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាព។ ដូចបានលើកឡើង សាក្សីរូបនេះបានបន្តបង្ហាញពីសក្ខីកម្មសាក្សីមុនៗ ដែលជាសក្ខានុពលគួរឱ្យអាចជឿជាក់ជាភស្តុតាងបាន ។ សំខាន់ជាងនេះ ការរំលោភវិធាន ៨៨(២) នាំឱ្យប៉ះពាល់សិទ្ធិជនជាប់ចោទទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។ ក្រុមអ្នកឃ្លាំមើលតុលាការ សូមជំរុញតុលាការបន្ថែមទៀតលើការដោះស្រាយបញ្ហានេះឱ្យកាន់តែឆាប់ កុំឱ្យប៉ះពាល់ធ្ងន់ធ្ងរលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។

## ៣. ការចូលរួម និងការការពារសាក្សី និងជនរងគ្រោះ

***វត្តមានដើមបណ្តឹងរដ្ឋប្បវេណី :*** ក្រុមអ្នកឃ្លាំមើលតុលាការកត់សម្គាល់ពីវត្តមានដើមបណ្តឹងរដ្ឋប្បវេណី ចូលរួមកិច្ចដំណើរការនីតិវិធីទាំង ២ថ្ងៃ នាសប្តាហ៍នេះ មានចំនួន ៩រូប ។

***អង្គជំនុំជម្រះលើកពីកង្វល់អំពីការបង្ហាញសក្ខីកម្មសាក្សីមុន :*** នៅថ្ងៃច័ន្ទនេះ អង្គជំនុំជម្រះបានចេញនូវ *"ការណែនាំថ្មី"* ចំពោះការដេញដោលសាក្សី និងជនជាប់ចោទក្នុងពេលដ៏សមរម្យ ។ ការណែនាំនេះត្រូវបានប្រកាសឡើងយោងតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិលោក **William Smith** ឱ្យបំភ្លឺកាលពីថ្ងៃពុធ នាសប្តាហ៍មុន ។ អង្គជំនុំជម្រះបានប្រកាសថា ខ្លួនមានឆន្ទានុសិទ្ធិសម្រេចថា តើត្រូវសួរជនជាប់ចោទមុនការបញ្ចប់សក្ខីកម្មសាក្សី ឬក៏យ៉ាងណា ។ អាស្រ័យហេតុនេះ ប្រធានអង្គជំនុំជម្រះលោក **និល ណុន** បានប្រកាសថា អង្គជំនុំជម្រះនឹងអនុម័តតាមករណីនិមួយៗដាច់ដោយឡែកពីគ្នា ក្នុងការចេញសេចក្តីសម្រេចលើបញ្ហានេះ ។

***មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញពីការសហការណ៍គ្នាមិនធ្លាប់មានពីមុន*** **:** ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានឯកភាពគ្នាចាត់តាំងមេធាវីក្រុម២ លោកស្រី **Silke Studzinsky** ជាតំណាងឱ្យមេធាវីទាំង៤ក្រុម នៅពេលអង្គជំនុំជម្រះផ្តល់ពេលសួរដេញដោលសាក្សី **គក ស្រស់** ។ កម្រិតសហការណ៍ដោយមិនបានសម្រេចជាមុនក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បញ្ជាក់ថា ជាការប៉ុងប៉ងគួរឱ្យកោតសរសើរ ដើម្បីលើកកំពស់ផលប្រយោជន៍ដើមបណ្តឹងទាំងមូល ។ ចំណែកពេលវេលាកំណត់សម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរដេញដោលលោក **គក ស្រស់** ក្រុមអ្នកឃ្លាំមើលតុលាការសង្កេតឃើញថា ការរៀបចំនេះធ្វើឱ្យពួកគេកាន់តែអភិវឌ្ឍទៅមុខ និងការតាំងសំណួរតាមលំដាប់ចំពោះសាក្សី ។

***ការអនុវត្តន៍សិទ្ធិសាក្សីក្នុងការមិនឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង*** **:** នាសប្តាហ៍នេះ អង្គជំនុំជម្រះបានបន្តយកចិត្តទុកដាក់លើការជូនដំណឹងដល់សាក្សី អំពីសិទ្ធិ និងកាតព្វកិច្ចចូលរួមនៅក្នុងសវនាការ ។ អាស្រ័យហេតុនេះ សាក្សីទីមួយៗត្រូវបានណែនាំដូចៗគ្នាអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយ ប្រសិនបើបារម្ភថាចម្លើយនោះអាចដាក់ពិរុទ្ធភាពលើខ្លួនឯង ។ លើសពីនេះទៀត សាក្សីមានកាតព្វកិច្ចនិយាយតែការពិតនូវអ្វីដែលខ្លួនបានដឹង បានឮ និង បានឃើញ ។

***មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបន្តកិច្ចប្រឹងប្រែងរក្សាសំលេងជនរងគ្រោះ*** **:** នាសប្តាហ៍នេះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបន្តកិច្ចប្រឹងប្រែងបញ្ចេញនូវកង្វល់របស់កូនក្តីខ្លួន ។ ការតាំងសំណួរមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ និងក្រុម៣ បានធ្វើឡើងដើម្បីទាញយកព័ត៌មានអំពីសាច់ញាតិ និងមនុស្សជាទីស្រឡាញ់របស់កូនក្តីខ្លួន ។

## ៤. ការគ្រប់គ្រងដំណើរការសវនាការ

***ការគ្រប់គ្រងផ្នែកតុលាការ*** **:** នាសប្តាហ៍នេះ សវនាការប្រព្រឹត្តទៅតែ ២ថ្ងៃប៉ុណ្ណោះ តាមកាលវិភាគកំណត់ ។ ជាទូទៅ អង្គជំនុំជម្រះបានបន្តដំណើរការសវនាការយ៉ាងទៀងទាត់ និងបញ្ចប់ទៅតាមពេលម៉ោងកំណត់ ។ ទោះបីជាការប្រឹងប្រែងគួរឱ្យកោតសរសើរ ក៏ដំណើរការសវនាការហាក់ប្រព្រឹត្តទៅយឺតជាងកាលវិភាគកំណត់ប្រហែល ២ថ្ងៃ ។

***វត្តមានភាគី*** **:** នាសប្តាហ៍នេះ ការិយាល័យសហព្រះរាជអាជ្ញាតំណាងដោយសហព្រះរាជអាជ្ញារងអន្តរជាតិលោក **Anees Ahmed** និងសហព្រះរាជអាជ្ញាជាតិតំណាងដោយលោក **តាន់ សេណារ៉ុង** ។ សហមេធាវីការពារក្តីអន្តរជាតិលោក **François Roux** អវត្តមានទាំងពីរថ្ងៃ ដោយសារលោកមានបេសកម្មបំពេញការងារនៅសាលាក្តីពិសេសនៅលីបង់ ។ ហេតុនេះ មេធាវីការពារក្តីជាតិលោក **ការ សាវុធ** ការពារជនជាប់ចោទ ។ គួរឱ្យកត់សម្គាល់ ទីប្រឹក្សាច្បាប់អន្តរជាតិលោកស្រី **Héleyn Unac** បានមានវត្តមាន កំឡុងពេលសវនាការ ។ ចំណែកមេធាវីប្រឹក្សាសាក្សី គឺលោក **គង់ សំអុន** ក៏មានវត្តមានដែរតាមការស្នើសុំ ។

***វត្តមានសាធារណៈជន*** **:** ដំណើរការសវនាការនាសប្តាហ៍នេះ សាធារណៈជនបានចូលរួមយ៉ាងច្រើន ដោយសារការបន្តគាំទ្រពីអង្គភាពកិច្ចការសាធារណៈនៃអ.វ.ត.ក. ។ នៅថ្ងៃច័ន្ទ មានសាធារណៈជនចូលរួមស្តាប់សវនាការរហូតដល់ ៤៦៤នាក់ មកពីក្រុងតាខ្មៅ និងស្រុកអង្គស្នួល ខេត្តកណ្តាល ។ លើសពីនេះទៀត ក៏មានអ្នកសារព័ត៌មានប្រមាណជា ៣១នាក់ និងក្រុមបុគ្គលិកបំរើ

ការងារតាមបណ្តាអង្គការជាតិ និងអន្តរជាតិ បានចូលរួមផងដែរ ។ ចំណែកឯ កិច្ចដំណើរការសវនាការនៅថ្ងៃអង្គារ មានប្រជាពលរដ្ឋចំនួន ១៨២នាក់ មកពីស្រុកសំរោងទង និង ប្រមាណ ២២០នាក់ មកពីស្រុកឧត្តុង ខេត្តកំពង់ស្ពឺ ។

***អង្គជំនុំជម្រះប្រកាសសេចក្តីសម្រេចស្តីពីការបែងចែកម៉ោងសួរដេញដោលសាក្សី :*** នៅព្រឹកថ្ងៃច័ន្ទ អង្គជំនុំជម្រះ ឆ្លើយតបទៅនឹងសំណើរបស់លោកស្រីមេធាវី **Silke Studzinsky** ។ លោកស្រីបានស្នើថា អង្គជំនុំជម្រះគួរអនុញ្ញាតដល់ភាគី អាចតាំងសំណួរដែលមិនទាន់សួរតាមរយៈអង្គជំនុំជម្រះ នៅពេលសាក្សីបញ្ចប់សក្ខីកម្មរបស់ខ្លួន ។ អង្គជំនុំជម្រះបានច្រានចោលសំណើនេះដោយបញ្ជាក់ថា បញ្ហានេះបានកំណត់រួចហើយ ដើម្បីកាត់បន្ថយការអូសបន្លាយម៉ោងពេលបានបែងចែកដល់ភាគី ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយអង្គជំនុំជម្រះបានបង្ហាញឆន្ទៈបត់បែនក្នុងការអនុវត្តវិធានរបស់ខ្លួន ។ ដូច្នេះ នៅរសៀលថ្ងៃអង្គារ អង្គជំនុំជម្រះបានដេញដោលលោក **សួស ធី** ស្តីពីឯកសារ ដែលលោកស្រី **Silke Studzinsky** ប៉ុនប៉ងតទល់ជាមួយសាក្សី ។

***វិន័យក្នុងសាលតុលាការ :*** នៅពេលអង្គជំនុំជម្រះសួរដេញដោលលោក **គក ស្រស់** នៅថ្ងៃច័ន្ទ នាសប្តាហ៍នេះ លោកចៅក្រម **Lavergne** បានសួរសាក្សីអំពីការបាត់ការចងចាំរបស់គាត់នូវបញ្ហាដែលកើតមានឡើង ។ លោកចៅក្រមបានបង្ហាញពីមន្ទិលសង្ស័យយ៉ាងខ្លាំង អំពីអលទ្ធភាពរបស់សាក្សីក្នុងការចងចាំនូវអំណះអំណាងពីមុនចំពោះមុខសហចៅក្រមស៊ើបអង្កេតកាលពីមួយឆ្នាំមុន។ លោកបានរំលឹកសាក្សីថា កាលណាសាក្សីសម្រេចចូលរួមសវនាការ សាក្សីត្រូវតែសហការណ៍ និងបញ្ជាក់នូវការពិត ។ នៅពេលមិនមានប្រសិទ្ធិភាព លោកចៅក្រមបានព្យាយាមស្នើយោបល់ទៀតថា ចំពោះបញ្ហា *"ឈឺចាប់"* និងបទពិសោធន៏ដ៏ខ្លោចផ្សាទាំងនេះ (ខុសពីមនុស្សសាមញ្ញ) វាហាក់ដូចជាមានការភ្ញាក់ផ្អើលខ្លាំងណាស់ ដែលធ្វើឱ្យសាក្សីហាក់បាត់បង់ទាំងស្រុងនូវការចងចាំដ៏មានសារសំខាន់ទាំងនោះ។ ទន្ទឹមនឹងនេះ សាក្សីបានឆ្លើយតបថា សព្វថ្ងៃគាត់ផ្តោតអារម្មណ៍តែទៅលើការរកស៊ីចិញ្ចឹមគ្រួសារគាត់តែប៉ុណ្ណោះ ។ ក្រុមអ្នកឃ្លាំមើលតុលាការមានការចាប់អារម្មណ៏ និងមានការយល់ខុសគ្នាចំពោះសំណួរលោកចៅក្រម **Lavergne** ថាតើការសួរដេញដោលរបស់លោកមានភាពសមស្រប ឬយ៉ាងណា ។ មតិមួយគិតថា ការសាកសួរបែបនេះ គឺមានលក្ខណៈសមស្របទាំងស្រុងស្ថិតក្នុងកាលៈទេសៈនេះ ឯមតិមួយទៀតថា លោកចៅក្រមគួរប្រុងប្រយ័ត្នអំពីការប៉ះទង្គិចផ្លូវចិត្តរបស់សាក្សី ។ ជាការពិតណាស់ដែលថា សាក្សីអាចបាត់ការចងចាំ ក្នុងករណីដែលសាក្សីបានរងនូវភាពតានតឹងមិនប្រក្រតី ដោយសារតែព្រឹត្តិការណ៍ដ៏រន្ធត់នោះ ។

## តារាងគ្រប់គ្រងពេលវេលា ៖

| ថ្ងៃ/ កាលបរិច្ឆេទ | ម៉ោងចាប់ផ្តើម | សម្រាក ពេលព្រឹក | សម្រាក អាហារថ្ងៃ ត្រង់ | សម្រាក ពេលរសៀល | ផ្អាកសវនាការ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ២៧/០៧/០៩ | ០៩.០៥ | ១០.២៥ – ១០.៤០ | ១២.០០-១.៣០ | ២.៤៥ - ៣.០០ | ៤.២០ | ៥ ម៉ោង ១៥នាទី |
| ថ្ងៃអង្គារ ២៨/០៧/០៩ | ០៩.០៥ | ១០.២៥ – ១០.៤០ | ១២.០០ -១.៣០ | ២.៥០ - ៣.២០ | ៤.១០ | ៤ ម៉ោង ៥០នាទី |

ចំនួនម៉ោងមធ្យមក្នុងសវនាការ១ថ្ងៃ ៥ ម៉ោង ៣នាទី

ចំនួនម៉ោងសរុបក្នុង១សប្តាហ៍៖ ១០ម៉ោង ៥នាទី

ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍សវនាការសរុប៖ ២១៥ម៉ោង និង៣០នាទី នៃរយៈពេលសវនាការ ៥០ថ្ងៃ កំឡុងពេល ១៤សប្តាហ៍

---

**អំពីកម្មវិធីអ្នកឃ្លាំមើលតុលាការកាត់ទោសខ្មែរក្រហម** ( "កម្មវិធី" ) ៖ ជាកម្មវិធីរបស់អង្គការ the Asian International Justice Initiative (AIJI) ដែលជាកិច្ចសហការណ៍រវាង U.C. Berkeley War Crimes Studies Center និង East-West Center ។

កម្មវិធីនេះចេញរបាយការណ៍ប្រចាំសប្តាហ៍ អំពីកិច្ចដំណើរការនីតិវិធីសវនាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ( អ.វ.ត.ក) ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ បច្ចុប្បន្ន កម្មវិធីនេះកំពុងតែឃ្លាំមើលដំណើរការនៃការកាត់ទោសលើសំណុំរឿង **កាំង ហ្កិចអ៊ាវ** ហៅ **ឌុច** ដែលជារឿងក្តីដំបូងឈានដល់ដំណាក់កាលជំនុំជម្រះ ។

របាយការណ៍ប្រចាំសប្តាហ៍នេះ ត្រូវបានរៀបចំដោយក្រុមឃ្លាំមើលតុលាការ ដែលដឹកនាំដោយលោកស្រី **Michelle Staggs** ជានាយិការងនៃអង្គការ AIJI ដែលមានសមាសភាពដូចខាងក្រោម ៖

**ក្រុមទី១**
- លោកស្រី **ជូ វិនាថ** ៖ ប្រធានកម្មវិធីសង្កេតការណ៍តុលាការនៃ CSD
- លោក **ង៉ែត សុវណ្ណនិត** ៖ បុគ្គលិកអង្គការ KID
- កញ្ញា **Yvette Anthony** ៖ សិង្ហបុរី
- លោក **Florian Hansen** ៖ អាល្លឺម៉ង់
- កញ្ញា **Caroline Ehlert Zurich** ៖ ស្វីស
- កញ្ញា **Deepika Sharma** ៖ សហរដ្ឋអាមេរិក

**ក្រុមទី២**
- កញ្ញា **សេក សុវណ្ណា** ៖ មេធាវី អង្គការ CLEC
- លោក **ភ័ក្រ្ត សាវ៉ន** ៖ បុគ្គលិកអង្គការ UNOHCHR
- កញ្ញា **Aviva Nababan** ៖ ឥណ្ឌូនេស៊ី
- កញ្ញា **Romana Weber** ៖ ស្វីស
- កញ្ញា **Binxin Zhang** ៖ ចិន
- លោក **Jaspreet Dosanjh** ៖ សហរដ្ឋអាមេរិក

កម្មវិធីនេះ បានសហការជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និង (KID) ដើម្បីផ្សព្វផ្សាយរបាយការណ៍នេះ ។ លោក-អ្នកអាចរកបាននូវរបាយការណ៍នេះជាភាសាខ្មែរ និងអង់គ្លេស នៅក្នុង www.csdcambodia.org ; www.kidcambodia.org និង http://Socrates.berkeley.edu/-warcrime/_ ។